ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តាចនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

-លេខ ៦០៣ ក្រ.ព.ទ
-ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩
-សំណុំរឿងព្រហ្មទណ្ឌលេខ **៧៤៩២**
ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨
-សំណុំរឿងស៊ើបសួរលេខ ៤៤៣៩
ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៨
-សំណុំរឿងជំនុំជម្រះ ៧៦៨
ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង ៨:00 នាទី នៅសាលសវនាការទី២ ដោយមានសមាសភាព៖

ក្រុមប្រឹក្សាជំនុំជម្រះ

-លោកស្រីអនុប្រធាន [redacted] ជាប្រធានក្រុមប្រឹក្សា
-លោកចៅក្រម [redacted] ជាចៅក្រមប្រឹក្សា
-លោកចៅក្រម [redacted] ជាចៅក្រមប្រឹក្សា

តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

-កញ្ញា [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ **៧៤៩២** ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨ ដែលមានជនជាប់ចោទ៖

១- ឈ្មោះ [redacted] **វុទ្ធី** ហៅ **ខ្ចិប** ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរ មិនពិតប្រាកដ កំរិតវប្បធម៌ថ្នាក់ទី៩ កើតនៅ[redacted]ត្តកណ្តាល ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះគ្មានលេខ ភូមិធំ សង្កាត់ពញាពន់ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ធឿន (រស់) ម្តាយឈ្មោះ [redacted] សុភាព (រស់) នៅលីវ ជាអនីតិជន ទោសពីមុន គ្មាន ។

មានលោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

ដីកាបង្គាប់ឃុំខ្លួនលេខ **៩៩០៧** "**ច**" **ដឃដ** ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

២- ឈ្មោះ [redacted] **រស្មី** ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរ មិនពិតប្រាកដ កំរិតវប្បធម៌ថ្នាក់ទី៧ កើតនៅភូ[redacted]ខេត្តកណ្តាល ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះគ្មានលេខ ភូមិធំ សង្កាត់ពញាពន់ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ [redacted] ហួន (រស់) នៅលីវ ទោសពីមុន គ្មាន ។

មានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

ដីកាបង្គាប់ឃុំខ្លួនលេខ **៩៩០៦** "**ច**" **ដឃដ** ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

Scanned with CamScanner

ជាប់ចោទពីបទ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រើអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ៥ ភូមិផ្សារលិច សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៣៥៣, ៣៥៧** នៃក្រមព្រហ្មទណ្ឌ និងមាត្រា **៤៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

- បានឃើញរបាយការណ៍សំយោគលេខ **៥៦/១៨ របក** ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៨ របស់អធិការនគរបាលខណ្ឌ ព្រែកព្នៅ ។

- បានឃើញដីកាសន្និដ្ឋានស្តាពរលេខ **៥៦៧ អ.ឃ.ន** ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ របស់អយ្យអមការសាលាដំបូងរាជធានីភ្នំពេញ ។

- បានឃើញដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ **៩២៤ ឧ.ច.ជ** ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

អត្ថហេតុនៃការចោទប្រកាន់មានដូចតទៅ ៖

កាលពីថ្ងៃទី០៥-១២-២០១៨ វេលាម៉ោង ០៥:៣០នាទី ពេលដែលជនរងគ្រោះឈ្មោះ [redacted] **វុទ្ធី** ភេទប្រុស អាយុ៤៩ឆ្នាំ បានជិះម៉ូតូ ០១គ្រឿងម៉ាក ហុងដាវ៉ែរ ពណ៌ខ្មៅ សេរីឆ្នាំ២០០២ ពាក់ផ្លាកលេខ ភ្នំពេញ 1KF-1968 ស្រាប់តែមានជនសង្ស័យ ០២នាក់ ឈ្មោះ [redacted] **វុទ្ធី** ភេទប្រុស អាយុ១៨ឆ្នាំ និងឈ្មោះ [redacted] **រស្មី** ភេទប្រុស អាយុ១៨ឆ្នាំ ជិះម៉ូតូម៉ាកហុងដាសេ១២៥ ពណ៌ខ្មៅ សេរីឆ្នាំ២០១៩ ពាក់ផ្លាកលេខ 1HI-5540 ចំនួន ០១គ្រឿង ស្របទិសគ្នា ជិះមកកៀក ជិតធ្វើសកម្មភាពឆក់យកទូរសព្ទដៃម៉ាក សាំសុង ពណ៌ស ស្រោមពណ៌ខ្មៅ ពីក្នុងហោប៉ៅអាវមុខរបស់ ជនរងគ្រោះ បានសម្រេចរួចជនសង្ស័យទាំង ០២នាក់នោះ បានរត់គេចខ្លួនបាត់ រួចជនរងគ្រោះក៏បានស្រែកឆោឡោ ជួយផងៗ ចោរឆក់ទូរសព្ទរបស់ខ្ញុំ រួចជិះម៉ូតូតាមពីក្រោយ រហូតដល់ចំណុចផ្លូវជាតិលេខ១៥១ កែវផ្លូវជាតិលេខ៥ ស្ថិតនៅភូមិផ្សារលិច សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ក៏ត្រូវបានកម្លាំងសមត្ថកិច្ចប៉ុស្តិ៍ព្រែកព្នៅ កំពុងឈរនៅគោលដៅនោះ ឃាត់ខ្លួនជនទាំង ០២នាក់នោះ ព្រមទាំងវត្ថុតាង យកមកសាកសួរ និងធ្វើសេត្តទីកន្លែង ឃើញថាមានសារធាតុញៀន ។

នាពេលសវនាការ

- ជនជាប់ចោទឈ្មោះ [redacted]**រស្មី** បានឆ្លើយថា៖ ខ្លួនពិតជាបានឆក់ទូរសព្ទដៃ ពីក្នុងហោប៉ៅអាវរបស់បុរសមិនស្គាល់ម្នាក់ ដែលជិះម៉ូតូតាមផ្លូវតែម្នាក់ឯង ប្រាកដមែន ។ ខ្លួន និងឈ្មោះ [redacted] **វុទ្ធី** បានជិះម៉ូតូទៅរែបបុរសនោះ ដោយខ្លួនជាអ្នកឌុប ហើយឈ្មោះ [redacted] **វុទ្ធី** ក៏ធ្វើសកម្មភាពឆក់យកទូរសព្ទពីបុរសនោះ បានសម្រេច រួចក៏ជិះគេច ខ្លួនតាមច្រកផ្សារព្រែកព្នៅ ហើយម្ចាស់ទូរសព្ទស្រែកថាចោរៗ ក៏ត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួនប្រគល់ឱ្យ សមត្ថកិច្ចតែម្តង ។ ចំពោះម៉ូតូម៉ាកហុងដា សេ១២៥ សេរីឆ្នាំ២០១៩ ខ្លួនបានខ្ចីពីអ្នកជិតខាងឈ្មោះ [redacted] **ម៉ៅ** ដោយប្រាប់ថាទៅឌុបស្រីមួយស្អែត តែក៏បែកគំនិតចេញឆក់តែម្តង ។

- ជនជាប់ចោទឈ្មោះ [redacted] **វុទ្ធី** បានឆ្លើយថា ៖ ខ្លួន និងឈ្មោះ [redacted] **រស្មី** ពិតជាបានធ្វើសកម្មភាពលួច យកទូរសព្ទពីបុរសម្នាក់នៅតាមផ្លូវប្រាកដមែន ។ ដោយខ្លួនជាអ្នកឆក់ ចំណែកឈ្មោះ [redacted] **រស្មី** ជាអ្នកបើក ។

- អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] **វុទ្ធី** ៖ នៅថ្ងៃកើតហេតុ ម៉ោង ៥:៣០នាទីព្រឹក ខ្លួនបានជិះម៉ូតូតែម្នាក់ឯងតាមផ្លូវជាតិលេខ៥ ក្នុងគោលបំណងទៅផ្សារព្រែកព្នៅ មកដល់ចំណុចវត្តព្រែកព្នៅ ក៏ស្រាប់តែ មានជនសង្ស័យ ០២នាក់ ជិះម៉ូតូ ០១គ្រឿងម៉ាក ហុងដាសេ១២៥ ពណ៌ខ្មៅ សេរីឆ្នាំ២០១៩ ជិះម៉ូតូមកទន្ទឹមនឹងខ្លួន ស្រាប់តែ

គ្នាវាម្នាក់ទៀត ជិះពីក្រោយបានឆក់យកទូរសព្ទខ្លួន ដែលដាក់ក្នុងហោប៉ៅអាវរួចក៏ជិះគេចទៅមុខ រួចបត់ចូល ផ្សារព្រែកឆ្មៅ ហើយខ្លួនក៏ជិះដេញតាមពីក្រោយ ទឹងបានបុកម៉ូតូវាឲ្យដួល ហើយក៏ស្រែកឲ្យប្រជាពលរដ្ឋជួយចាប់ និងបានយកទូរសព្ទមកវិញ ។ ពេលពួកវាឆក់គឺបានចាត់ឯកសារមួយចំនួន ហើយឯកសារទាំងនោះវាបានទំលាក់ចោល តាមផ្លូវបាត់អស់ហើយ រកពុំឃើញទេ ។ ខ្លួនទាមទារសំណងជម្ងឺចិត្ត ចំនួន ៥000$ ។

- អំណានចម្លើយសាក្សីឈ្មោះ [redacted] ឌីណា ៖ នៅថ្ងៃកើតហេតុវេលាម៉ោង ៥:៣០នាទីព្រឹក ខ្លួនបានជិះម៉ូតូចេញពីផ្ទះឆ្ពោះទៅតាមបណ្តោយផ្លូវជាតិលេខ៥ ពីត្បូងទៅជើង ក្នុងគោលបំណងរង់ចាំឌុបម៉ួយ មកដល់ចំណុចកើតហេតុស្រាប់តែមានជនសង្ស័យចំនួន ០២នាក់ ជិះម៉ូតូហុងដាសេ១២៥ ពណ៌ខ្មៅ សេរីឆ្នាំ២០១៩ បើកស្របទិសគ្នា បានវ៉ាម៉ូតូខ្លួន ចំងាយប្រហែល ១00ម៉ែត្រ ភ្លាមនោះម្នាក់អង្គុយពីក្រោយក្រោកឈរ យកដៃស្តាំឆក់ទូរសព្ទមិនស្គាល់ ម៉ាក ពីក្នុងហោប៉ៅអាវមុខខាងឆ្វេង របស់ជនរងគ្រោះបានសម្រេច ជិះគេចខ្លួន ពេលនោះខ្លួនបានលឺសម្លេងជនរងគ្រោះ ស្រែកធោរឡោ ជួយផងៗចោរឆក់ទូរសព្ទរបស់ខ្ញុំ ខ្លួនក៏បានដេញតាមពីក្រោយជាមួយជនរងគ្រោះ ហើយក៏ត្រូវបាន សមត្ថកិច្ចល្បាតនៅទីនោះឃាត់ខ្លួនតែម្តង ។

- អំណានកំណត់ហេតុទទួលវត្ថុចាប់យក មាន៖

១. ទូរសព្ទដៃចំនួន ០២គ្រឿង ពណ៌ខៀវ ម៉ាកណូគាអិនចុចពិល (មិនដំណើរការ)

២. ម៉ូតូ ០១គ្រឿង ម៉ាកហុងដាសេ ១២៥ ពណ៌ខ្មៅ ពាក់ស្លាកលេខ 1HI-5540 លេខតួ និងលេខម៉ាស៊ីន MD125ME507199 (មិនប្រក្រតី) ។

- អំណានកំណត់ហេតុធ្វើតេស្តស្វែងរកសារធាតុញៀន ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] **រស្មី** និងឈ្មោះ [redacted] **វុទ្ធី** ជាលទ្ធផល វិជ្ជមាន ។

សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានធ្វើការសួរដេញដោលរួចមកឃើញថា ជនជាប់ចោទឈ្មោះ [redacted] **វុទ្ធី** ហៅ **ខ្ជិប**, ឈ្មោះ [redacted] **រស្មី** ស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] **វុទ្ធី** និងអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] **ឌីណា** ឃើញថា ពិតជាបានប្រព្រឹត្តអំពើ **លួចមានស្ថានទម្ងន់ទោស ដោយការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ៥ ភូមិផ្សារលិច សង្កាត់ព្រែកឆ្មៅ ខណ្ឌព្រែកឆ្មៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៣៥៣, ៣៥៧** នៃក្រមព្រហ្មទណ្ឌ និងមាត្រា **៤៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រាកដមែន ។ តំណាងអយ្យការ សុំតម្កល់បទចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្តាពរ ។

សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

- មេធាវី [redacted] ការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] **វុទ្ធី** បានធ្វើសេចក្តីសន្និដ្ឋានថា ៖ កូនក្តីរបស់ខ្លួនបានធ្លើយសារភាពដោយគ្មានលាក់លៀម ។ កូនក្តីរបស់ខ្លួនមិនបានប្រើអំពើហិង្សាទៅលើជនរងគ្រោះទេ ។ ខ្លួនស្នើ សុំឲ្យតុលាការ ពិចារណាកែប្រែបទចោទប្រកាន់ពីបទ **លួច ដោយហិង្សា** ទៅបទ **លួច** ធម្មតាវិញ និងសុំឲ្យ តុលាការបន្ធូរបន្ថយទោសឲ្យដល់កូនក្តីខ្លួនផង ។

- មេធាវី [redacted] ការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] **រស្មី** បានធ្វើសេចក្តីសន្និដ្ឋានថា ៖ កូនក្តីរបស់ខ្លួនបានធ្លើយសារភាព ហើយកូនក្តីរបស់ខ្លួនមិនបានប្រើអំពើហិង្សាទៅលើជនរងគ្រោះឡើយ ។ ខ្លួនស្នើសុំឲ្យតុលាការ កែប្រែបទចោទប្រកាន់ ពីមាត្រា **៣៥៧** មក **៣៥៦** នៃក្រមព្រហ្មទណ្ឌ និងផ្តល់ស្ថានសម្រាលដល់កូនក្តីខ្លួន ។

Scanned with CamScanner

សំដីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី សំណូមពរសុំឲ្យតុលាការបន្ធូរបន្ថយទោស ។

ជនជាប់ចោទឈ្មោះ [redacted] រស្មី សំណូមពរសុំឲ្យតុលាការបន្ធូរបន្ថយទោស ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី និងឈ្មោះ [redacted] រស្មី

-ក្រោយពីបានពិនិត្យឯកសារភស្តុតាងនានា

-ក្រោយពីបានពិនិត្យ និងពិចារណាតាមច្បាប់រួចហើយ

សំអាងហេតុ

១- តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៩២៤ "ឆ"ដដ ចុះថ្ងៃទី២៥-០២-២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] **វុទ្ធី** ភេទប្រុស អាយុ១៨ឆ្នាំ និងឈ្មោះ [redacted] **រស្មី** ភេទប្រុស អាយុ១៨ឆ្នាំ ពីបទ **លួចមានស្ថានទម្ងន់ទោស ដោយការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ៥ ភូមិផ្សារលិច សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៣៥៣, ៣៥៧** នៃក្រមព្រហ្មទណ្ឌ និង មាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មកតុលាការជំនុំជម្រះ ។

២- តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] **វុទ្ធី** និងឈ្មោះ [redacted] **រស្មី** មានភាពស្របគ្នាថា ៖ ខ្លួនពិតជាបានឆក់ទូរស័ព្ទដៃពីក្នុងហោប៉ៅរបស់ជនរងគ្រោះប្រាកដមែន ដោយឈ្មោះ [redacted] **រស្មី** ជាអ្នកឌុប និងឈ្មោះ [redacted] **វុទ្ធី** ជិះពីក្រោយជាអ្នកឆក់ ។

៣- តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **វុទ្ធី** និងសាក្សី ឈ្មោះ [redacted] **ឌីណា** មានភាពស៊ីសង្វាក់គ្នា ដែលថា នៅថ្ងៃកើតហេតុ ម៉ោង ៥:៣០នាទីព្រឹក ឈ្មោះ [redacted] **វុទ្ធី** បានជិះម៉ូតូតែម្នាក់ឯង ក៏មានជនសង្ស័យ ០២នាក់ ជិះម៉ូតូទៅរែប និងឈ្មោះ [redacted] **វុទ្ធី** និងម្នាក់ដែលជិះពីក្រោយបានធ្វើសកម្មភាពឆក់យកទូរស័ព្ទពីក្នុងហោប៉ៅអាវរបស់ឈ្មោះ [redacted] **វុទ្ធី** ។

៤- តាមកំណត់ហេតុធ្វើតេស្តស្វែងរកសារធាតុញៀន ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] **វុទ្ធី** និង ឈ្មោះ **សន រស្មី** ជាលទ្ធផល **វិជ្ជមាន** ។

៥- អំពើរបស់ជនជាប់ចោទ ឈ្មោះ [redacted] **វុទ្ធី** និងឈ្មោះ [redacted] **រស្មី** បានសម្តែងនូវចេតនាទុច្ចរិត ក្នុងការ ដកហូតនូវទ្រព្យសម្បត្តិរបស់ជនរងគ្រោះ **និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ទង្វើនេះបានធ្វើឲ្យប៉ះពាល់ ដល់ទ្រព្យសម្បត្តិរបស់ជនរងគ្រោះ សន្តិសុខសង្គម និងរបៀបរៀបរយសាធារណៈ ដែលច្បាប់បានកំណត់ថា ជាបទ ល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៣៥៣, ៣៥៧** នៃក្រមព្រហ្មទណ្ឌ និងមាត្រា **៤៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៦- មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ ៖

- ឈ្មោះ [redacted] វុទ្ធី ហៅ ខ្ចិប ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ
- ឈ្មោះ [redacted] រស្មី ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ

ពីបទ **លួចមានស្ថានទម្ងន់ទោស ដោយការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ៥ ភូមិផ្សារលិច សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៣៥៣, ៣៥៧** នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៧- តាមសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ក្រោយពីបានធ្វើការសួរដេញដោលរួចមកឃើញថាជនជាប់ចោទ ឈ្មោះ [redacted] **វុទ្ធី ហៅ ខ្ចិប, ឈ្មោះ [redacted] រស្មី** ស្នាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] **វុទ្ធី** និង អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] **ឌីណា** ឃើញថា ពិតជាបានប្រព្រឹត្តអំពើ **លួចមានស្ថានទម្ងន់ទោស ដោយការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ៥ ភូមិផ្សារលិច សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៣៥៣, ៣៥៧** នៃក្រមព្រហ្មទណ្ឌ និងមាត្រា **៤៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រាកដមែន។ តំណាងអយ្យការ សុំតម្កល់បទចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្តាពរ ។ តុលាការបានពិចារណារួចហើយ ។

៨- តាមសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **វុទ្ធី** និងឈ្មោះ [redacted] **រស្មី** បានសន្និដ្ឋានប្រហាក់ប្រហែលគ្នា ៖ សុំឱ្យតុលាការកែប្រែបទចោទប្រកាន់ពីបទ **លួច ដោយហិង្សា** មាត្រា **៣៥៧** មកបទ **លួច** ធម្មតា មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។ តុលាការបានពិចារណារួចហើយ ។

៩- តាមសម្តីចុងក្រោយជនជាប់ចោទឈ្មោះ [redacted] **វុទ្ធី** និងឈ្មោះ [redacted] **រស្មី** បានសុំឱ្យតុលាការបន្ធូរបន្ថយទោស យើងបានពិចារណារួចហើយ ។

១០- ជនរងគ្រោះឈ្មោះ [redacted] **វុទ្ធី** បានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងដំណាក់កាលចៅក្រមស៊ើបសួរ ដោយប្តឹងទាមទារសំណងជម្ងឺចិត្ត ចំនួន ៤000$ (បួនពាន់) ដុល្លារ ពីជនជាប់ចោទ គប្បីតុលាការពិចារណា និងសម្រេចតាមសភាពជាក់ស្តែង ។

១១- វត្ថុចាប់យក មាន ៖ ទូរសព្ទដៃចំនួន ០២គ្រឿង ពណ៌ខៀវ ម៉ាកណូគាអិនចុចពិល (មិនដំណើរការ)

គប្បីតុលាការសម្រេចរឹបអូសតាមមាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

- ចំពោះម៉ូតូ ០១គ្រឿង ម៉ាកហុងដាសេ ១២៥ ពណ៌ខ្មៅ ពាក់ស្លាកលេខ 1HI-5540 លេខតួ និងលេខម៉ាស៊ីន MD125ME507199 (មិនប្រក្រតី) តំណាងអយ្យការបានប្រគល់ឱ្យម្ចាស់ដើមវិញរួចហើយ គប្បីតុលាការមិនយកមកពិចារណា និងសម្រេចឡើយ ។

ហេតុដូច្នេះសម្រេច

១- ផ្តន្ទាទោស ៖

- ឈ្មោះ [redacted] **វុទ្ធី** ហៅ **ខ្ចិប** ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ
- ឈ្មោះ [redacted] **រស្មី** ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ

ដាក់ពន្ធនាគារកំណត់ម្នាក់ៗកំណត់រយៈពេល **០៣ (បី) ឆ្នាំ** គិតចាប់ពីថ្ងៃឃុំខ្លួនបណ្តោះអាសន្ន និងពិន័យជាប្រាក់ម្នាក់ៗចំនួន **១,000,000 (មួយលាន) រៀល** ចូលថវិការជាតិ ។

Scanned with CamScanner

ពីបទ **លួចមានស្ថានទម្ងន់ទោស ដោយការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ៥ ភូមិផ្សារលិច សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៣៥៣, ៣៥៧** នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២- បង្គាប់ឲ្យឈ្មោះ [redacted] **រុទ្ធី** និងឈ្មោះ [redacted] **ស្មី** សងសំណងជម្ងឺចិត្តទៅឈ្មោះ [redacted] **ទ្ធី** ចំនួន ២,០០០,០០០ (ពីលាន) រៀល ការទាមទារលើសពីនេះបដិសេធចោល ។

៣- វិបរអូសវត្ថុចាប់ឃកមាន ៖ ទូរសព្ទដៃចំនួន ០២គ្រឿង ពណ៌ខៀវ ម៉ាកណូគាអិនចុចពិល(មិនដំណើរការ)។

សាលក្រមនេះជំនុំជម្រះជាអសាធារណៈ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **រុទ្ធី** និងឈ្មោះ [redacted] **រស្មី** កំពាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **រុទ្ធី** និងប្រកាសជាអសាធារណៈនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩ ។

បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

ក្រឡាបញ្ជី	**ចៅក្រមប្រឹក្សា**	**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា
[redacted]		

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បត្តិ៍ ៨កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩

ក្រឡាបញ្ជី

[redacted]

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

Scanned with CamScanner